# ព្រះរាជក្រឹត្យ

នស/រកត/០៩៩៦/៧២

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
## ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម
## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង
## កម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់សេចក្តីប្រកាសចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ និង សេចក្តីថ្លែង–ការណ៍ របស់លោក អៀង សារី ប្រធានចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៩៦
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានលើកលែងទោសអោយ លោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានផ្តន្ទាទោសប្រហារជីវិតបង់ និង រឹបអូស ទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និង ចំពោះទោសដែលបានកំណត់ដោយច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យអោយនៅក្រៅច្បាប់

ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ៩៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

មាត្រា ២: ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

មាត្រា ៣: ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេចជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៦

**នរោត្តម សីហនុ**

បានក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**